# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តត្បូងឃ្មុំ

## តា ង នា ម ប្រ ជា រា ស្ត្រ ខ្មែ រ
## សាលាដំបូងខេត្តត្បូងឃ្មុំ

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៥៣១ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ -
ជំនុំជម្រះលេខ៦៦ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ -
សាលក្រមព្រហ្មទណ្ឌលេខ:១៣០(ច) ចុះថ្ងៃទី០២ ខែ មីនា ឆ្នាំ២០២២

បើកសវនាការជាសាធារណៈ នៅសាលសវនាការទី១ នៃសាលាដំបូងខេត្តត្បូងឃ្មុំ។

កាលបរិច្ឆេទបើកសវនាការៈ នៅថ្ងៃព្រហស្បតិ៍ ១រោច ខែមាឃ ត្រីស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២។

កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃពុធ ១៤រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២។

### សមាសភាពជំនុំជម្រះ

លោក [redacted] ឋានៈចៅក្រម ជាចៅក្រមជំនុំជម្រះ

### តំណាងអយ្យការ

លោក [redacted] ឋានៈព្រះរាជអាជ្ញារង ជាតំណាងអយ្យការ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជីសវនាការ

ដើម្បីជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌលេខៈ ៥៣១ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ ដែលមានជនជាប់ចោទៈ

ឈ្មោះ [redacted] វ៉ន ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត ភូមិ[redacted] ខេត្តកំពង់ចាម អាសយដ្ឋានមុនពេលឃាត់ខ្លួន ភូមិព្រីត ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ឪពុកឈ្មោះ [redacted] ឃឹម (រ) ម្ដាយឈ្មោះ [redacted] សុខន (រ) ប្រពន្ធឈ្មោះ [redacted] ស្រីម៉ៅ មានកូនចំនួន០២នាក់ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

ពីបទ ហិង្សាដោយចេតនា ប្រព្រឹត្តិនៅភូមិព្រីត ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

- បានឃើញសំណុំរឿងជំនុំជម្រះលេខ៦៦ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តត្បូងឃ្មុំ។
- បានឃើញដីកាដំណោះស្រាយ បញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥១ ព្រ.ទ១ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២។

Scanned with CamScanner

- បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ១១០/២០២២ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ ២០២២ របស់ប្រធានសាលាដំបូងខេត្តត្បូងឃ្មុំ។

**១. ផ្នែកសំអាងហេតុ**

**១.១ អំពីអង្គហេតុ**

កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ ជនជាប់ចោទឈ្មោះ [redacted] វ៉ុន ក្នុងស្ថានភាពស្រវឹងស្រា បានមកផ្ទះជនរងគ្រោះឈ្មោះ [redacted] អុក ភេទស្រី អាយុ៦៨ឆ្នាំ ស្ថិតនៅភូមិព្រីត ឃុំក្រែក ស្រុក ពញាក្រែក ខេត្តត្បូងឃ្មុំ ដើម្បីហៅប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] ស្រីម៉ៅ កំពុងនៅផ្ទះរបស់ជនរងគ្រោះឲ្យមករស់នៅជាមួយខ្លួន តែពេលនោះជនជាប់ចោទ និងឈ្មោះ [redacted] ស្រីម៉ៅ ក៏បានឈ្លោះទាស់ទែងប្រតាយប្រតប់គ្នា ឃើញដូច្នោះ ជនរងគ្រោះបានចូលទៅឃាត់ ស្រាប់តែត្រូវបានជនត្រូវចោទដាល់ចំនួន០១ដៃត្រូវចំដងខ្លួន ធ្វើឲ្យជនរងគ្រោះដួលត្រូវចំសសរផ្ទះបណ្ដាលឲ្យរងរបួសក្បាល និងជាំភ្នែក។

**១.២ អំពីភស្តុតាង និងកំណត់ហេតុនានា**

**- វត្ថុតាង និងកំណត់ហេតុនានាក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌**

១.២.១ កំណត់ហេតុបណ្ដឹង ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុកពញាក្រែកៈ ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] អុក ឆ្លើយថា កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ ២០២១ វេលាម៉ោង១៦ និង០០នាទី ខ្លួនកំពុងចម្រាញ់ខ្លាញ់ជ្រូក ពេលនោះឈ្មោះ [redacted] វ៉ុន ហៅ អាឡេះ ភេទប្រុស អាយុ២៦ឆ្នាំ នៅភូមិព្រីត ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ បានមករករឿងប្រពន្ធវាឈ្មោះ [redacted] ស្រីម៉ៅ អាយុ២១ឆ្នាំ ត្រូវជាចៅខ្លួន ពេលនោះខ្លួនបានឃាត់ឈ្មោះ [redacted] វ៉ុន បានដាល់ខ្លួន០១ដៃបណ្ដាលឲ្យខ្លួនដួល បន្ទាប់មកបានធាក់ខ្លួនចំនួន០២ជើងទៀត បណ្ដាលឲ្យដួលត្រូវសសរផ្ទះបណ្ដាលឲ្យរងរបួសជាំភ្នែកស្ដាំ និងបែកក្បាល។ ខ្លួនទាមទារសំណង២លានរៀលដើម្បីព្យាបាល។

១.២.២ កំណត់ហេតុស្ដាប់ចម្លើយឈ្មោះ [redacted] វ៉ុន ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុកពញាក្រែកៈ ឈ្មោះ [redacted] វ៉ុន បានឆ្លើយថា ខ្លួន និងប្រពន្ធខ្លួនឈ្មោះ [redacted] ស្រីម៉ៅ ក្រោយពីរៀបការរួចនៅឆ្នាំ២០១៨ ខ្លួន និងប្រពន្ធបានរស់នៅជាមួយឪពុកម្ដាយខាងប្រពន្ធ និងយាយក្មេកឈ្មោះ [redacted] អុក រហូតមកដល់បច្ចុប្បន្ននេះ។ នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង៨ និង០០នាទី យាយក្មេកខ្លួននិយាយថា ខ្លួនមិនដែលមើលថែគាត់ទេ ហើយខ្លួនក៏និយាយថា មានពេលណាមើលថែ បើរវល់តែជៀរជ័រកៅស៊ូ គាត់ខឹងខ្លួនបានដេញខ្លួនមិនឲ្យនៅផ្ទះជាមួយគាត់ រហូតដល់ម៉ោងប្រហែល១៥និង៣០នាទី ថ្ងៃដដែល ហើយហៅប្រពន្ធខ្លួនឲ្យទៅរស់នៅក្នុងផ្ទះខ្លួនដែលម្ដាយចែកឲ្យស្ថិតនៅភូមិព្រីតជាមួយគ្នា។ ប្រពន្ធខ្លួនមិនព្រមទៅជាមួយខ្លួនទេ ពេលនោះខ្លួនបានចាប់ទាញដៃឲ្យឡើងម៉ូតូ តែប្រពន្ធខ្លួនមិនព្រម បានប្រតាយប្រតប់គ្នាជាមួយប្រពន្ធខ្លួន ក្នុងពេលនោះ យាយក្មេកបានចូលមកឃាត់ ហើយខ្លួនបានគ្រវាសដៃត្រូវគាត់បណ្ដាលឲ្យគាត់ដួលបោកក្បាលត្រូវចំ



Scanned with CamScanner

ជ្រុងសសរថ្ម របះក្បាលហូរឈាម ពេលនោះប្រពន្ធខ្លួនបានយកគល់អុសមកវាយខ្លួនចំក្បាលខ្លួន របួសមួយកន្លែង រហូតដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២១ ពេលព្រឹក សមត្ថកិច្ចបានចាប់ខ្លួនតែម្តង។

១.២.៣ កំណត់ហេតុស្រាវជ្រាវ និងពិនិត្យកន្លែងកើតហេតុ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុក ពញាក្រែក។

១.២.៤ សៀវភៅរូបថត ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុក ពញាក្រែក។

១.២.៥ របាយការណ៍លេខ១០៤២/២០២១ រ.ប.ក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុក ពញាក្រែក។

**- ការទទួលវត្ថុតាង និងការចោទប្រកាន់**

១.២.៦ កំណត់ហេតុស្រាវជ្រាវ និងពិនិត្យកន្លែងកើតហេតុ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២១ និង សៀវភៅរូបថត ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុក ពញាក្រែក។

១.២.៧ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ៤០០ អយក/២១ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ និងដីកាសន្និដ្ឋានស្ថាពរលេខ០២ អយ.ង/២១ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ សម្រេចចោទប្រកាន់ ឈ្មោះ [redacted] វ៉ុន (សាវតារជាតិខាងលើ) ពីបទហិង្សាដោយចេតនា ប្រព្រឹត្តិនៅភូមិព្រីត ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

**- កិច្ចស៊ើបសួរ ដោយចៅក្រមស៊ើបសួរ**

១.២.៨ កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង, កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ សម្រេចដាក់ជនត្រូវចោទឈ្មោះ [redacted] វ៉ុន ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ ហិង្សាដោយចេតនា ប្រព្រឹត្តិនៅភូមិព្រីត ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

១.២.៩ កំណត់ហេតុសួរចម្លើយជនត្រូវចោទឈ្មោះ [redacted] វ៉ុន ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១៖ ជនត្រូវចោទឆ្លើយថា កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ ខ្លួនបានទៅផ្ទះរបស់ជនរងគ្រោះឈ្មោះ [redacted] អុក ត្រូវជាយាយក្មេករបស់ខ្លួន ដើម្បីហៅប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] ស្រីម៉ៅ ទៅផ្ទះវិញ។ ប្រពន្ធខ្លួនមិនព្រមទៅផ្ទះវិញ ខ្លួនក៏បានប្រតាយប្រតប់គ្នាជាមួយនឹងប្រពន្ធ ហើយឈ្មោះ [redacted] អុក បានចូលទៅឃាត់។ បន្ទាប់មក ខ្លួនក៏បានក្រវាសដៃត្រូវចំគាត់ចំនួន០១ដៃ បណ្តាលឲ្យដួលត្រូវចំសសរផ្ទះ របួសចំក្បាល។ ពេលប្រតាយប្រតប់ ខ្លួនមិនបានប្រើអាវុធទេ។

១.២.១០ កំណត់ហេតុស្តាប់ចម្លើយជនរងគ្រោះ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១៖ ជនរងគ្រោះឈ្មោ[redacted] អុក បានឆ្លើយថា នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ ឈ្មោះ [redacted] វ៉ុន បានឈ្លោះប្រកែកប្រតាយប្រតប់គ្នាជាមួយប្រពន្ធឈ្មោះ [redacted] ស្រីម៉ៅ ឃើញដូច្នេះ ខ្លួនចូលឃាត់ស្រាប់តែឈ្មោះ [redacted] វ៉ុន បានក្រវៀសដៃត្រូវខ្លួនបណ្តាលឲ្យដួលបោកក្បាលទៅនឹងសសរ។ ក្រោយមកប្អូនរបស់ខ្លួន



Scanned with CamScanner

បានទៅពេទ្យ ហើយខ្លួនព្យាបាលរយៈពេល១សប្តាហ៍ ក៏បានជាសះស្បើយវិញ។ ខ្លួនបានព្យាបាលអស់ជាង១លានរៀល។ ឈ្មោះ [redacted] វ៉ុន មិនបានប្រើអាវុធវាយខ្លួននោះទេ។ ក្រោយពេលខ្លួនដួល ឈ្មោះ [redacted] វ៉ុន បានវាយខ្លួនបន្តទៀត។ ខ្លួនមិនទាមទារសំណងការខូចខាតទេ។ ខ្លួនបានដកពាក្យបណ្តឹងរួចហើយ។

១.២.១១ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន លេខ១១១៤ ព្រទ១និង ដីកាបង្គាប់ឲ្យឃុំខ្លួន លេខ៨៤៧ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ បានសម្រេច និងបង្គាប់ឲ្យឃុំខ្លួនឈ្មោះ [redacted] វ៉ុន។

១.២.១២ ដីកាសម្រេចឲ្យដោះលែងនៅក្រៅឃុំលេខ៣៩១ ព្រ.ទ២, ដីកាបង្គាប់ឲ្យដោះលែងលេខ៣៩២ ព្រ.ទ២ និងដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ៣៩៣ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១៖ សម្រេចដោះលែងជនត្រូវចោទឈ្មោះ [redacted] វ៉ុន និង ដាក់កាតព្វកិច្ចតាមផ្លូវតុលាការឲ្យជនត្រូវចោទអនុវត្ត។

១.២.១៣ ដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៥១ ព្រ.ទ១ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ បានសម្រេចបញ្ជូនជនត្រូវចោទឈ្មោះ [redacted] វ៉ុន ទៅជំនុំជម្រះ ពីបទ ហិង្សាដោយចេតនា បទល្មើសព្រហ្មទណ្ឌដែលមានចែង និង បញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

១.៣ សវនាការពិភាក្សាដេញដោល

១.៣.១ ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] វ៉ុន។

១.៣.២ ក្រឡាបញ្ជីអានចម្លើយជនរងគ្រោះឈ្មោះ [redacted] អុក។

១.៣.៣ តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានទោស៖ ក្រោយពីបានពិភាក្សាដេញដោលនៅក្នុងអង្គសវនាការ អំណានចម្លើយជនជាប់ចោទ, អំណានចម្លើយជនរងគ្រោះ និងឯកសារពាក់ព័ន្ធអាចឲ្យសន្និដ្ឋានបានថា ជនជាប់ចោទឈ្មោះ [redacted] វ៉ុន ពិតជាបានប្រើអំពើហិង្សាទៅលើជនរងគ្រោះឈ្មោះ [redacted] អុក ដែលត្រូវជាយាយក្មេក បណ្តាលឲ្យរងរបួស។ ហេតុដូច្នេះ រក្សាបទចោទលើឈ្មោះ [redacted] វ៉ុន ពីបទ ហិង្សាដោយចេតនា បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។ ស្នើសុំឲ្យតុលាការប្រកាសពិរុទ្ធភាព និងផ្តន្ទាទោសជនជាប់ចោទទៅតាមផ្លូវច្បាប់។

១.៣.៤ មេធាវីសន្និដ្ឋានការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វ៉ុន៖ សុំឲ្យតុលាការសម្រេចតាមផ្លូវច្បាប់។

**១.៤ ការយល់ឃើញ**

១.៤.១ ដីកាដំណោះស្រាយលេខ៥១ ព្រ.ទ១ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ បានសម្រេចបញ្ជូនទៅសាលាដំបូងខេត្តត្បូងឃ្មុំដើម្បីជំនុំជម្រះនូវ សំណុំរឿងព្រហ្មទណ្ឌលេខ៥៣១ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ វត្តតាង បញ្ជីរាយនាមជនទាក់ទិនក្នុងសំណុំរឿង និង ជនជាប់ចោទឈ្មោះ [redacted] វ៉ុន ហិង្សាដោយចេតនា បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

តាមបញ្ញត្តិមាត្រា២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អាចឲ្យតុលាការលើកយកសំណុំរឿងខាងលើមកជំនុំជម្រះបាន។

១.៤.២ របាយការណ៍លេខ១០៤២/២០២១ រ.ប.ក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុក ពញាក្រែក បានសន្និដ្ឋានថា ឈ្មោះ [redacted] វ៉ុន (សាវតាជាតិខាងលើ) ពិតជាបានប្រព្រឹត្តអំពើល្មើស ហិង្សាដោយចេតនា កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ ប្រាកដមែន។

១.៤.៣ តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] វ៉ុន បានឆ្លើយសារភាពថា ខ្លួនពិតជាបាន គ្រវាសដៃត្រូវជនរងគ្រោះឈ្មោះ [redacted] អុក ដែលត្រូវជាយាយក្មេក បណ្តាលឲ្យដួលត្រូវសសររងរបួស ប្រាកដមែន។ តាមរបាយការណ៍របស់អធិការដ្ឋាននគរបាលស្រុកពញាក្រែក ចម្លើយសារភាពរបស់ជនជាប់ចោទ, ចម្លើយរបស់ជនរងគ្រោះ និង វត្ថុតាងជារូបថត និងកំណត់ហេតុនានាដែលកសាងដោយមន្ត្រីនគរបាលយុត្តិធម៌ អាចឲ្យតុលាការជឿជាក់ថា ជនជាប់ចោទពិតជាបានប្រើហិង្សាដោយជនរងគ្រោះ ហើយអំពើនេះ គឺជាបទល្មើសព្រហ្មទណ្ឌ ដែលជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទៅតាមច្បាប់កំណត់។

១.៤.៤ នៅពេលសវនាការ តំណាងអយ្យការ បានសន្និដ្ឋាន សុំឲ្យតុលាការប្រកាសពិរុទ្ធភាព និងផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] វ៉ុន ពីបទ ហិង្សាដោយចេតនា បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។ តុលាការយល់ឃើញថា ការស្នើសុំរបស់តំណាងអយ្យការមានភាពត្រឹមត្រូវគប្បីសម្រេចតាមការស្នើសុំ។

១.៤.៥ អំពើប្រព្រឹត្តរបស់ជនជាប់ចោទខាងលើ បានធ្វើឲ្យប៉ះពាល់ដល់សន្តិសុខសង្គម ស្មារតី សុខភាពរបស់អ្នកដទៃ និងទំនៀមទំលាប់ប្រពៃណីដ៏ល្អផូរផង់របស់ជាតិ ។

១.៤.៦ នៅពេលប្រព្រឹត្តបទល្មើសជនជាប់ចោទជានីតិជន មិនមានសញ្ញាណណាមួយបញ្ជាក់ថាមានវិប្បល្លស្មារតីនោះទេ ហេតុនេះជនជាប់ចោទមានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ។

១.៤.៧ ជនជាប់ចោទបានធ្វើសកម្មភាពហិង្សាទៅលើជនរងគ្រោះក្នុងស្ថានបន្ទាន់បង្ខំ ដែលបានធ្វើឲ្យជនរងគ្រោះត្រូវជាយាយក្មេងរងរបួស។ ជនជាប់ចោទមិនធ្លាប់ប្រព្រឹត្តិបទល្មើសពីមុនមក ហើយជនរងគ្រោះដែលត្រូវជាយាយក្មេកបានដកពាក្យបណ្តឹង និងស្នើសុំឲ្យតុលាការដោះលែងចៅប្រសាររបស់ខ្លួនវិញ។ ហេតុនេះ គប្បីផ្តល់ស្ថានសម្រាលទោសដល់ជនជាប់ចោទ ដោយការព្យួរទោសធម្មតា។

**សេចក្តីសន្និដ្ឋាន**

មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] វ៉ុន ពីបទ ហិង្សាដោយចេតនា ប្រព្រឹត្តិនៅចំណុចភូមិព្រីត ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ ដូចដែលតំណាងអយ្យការ និងចៅក្រមស៊ើបសួរបានចោទប្រកាន់។ ហេតុនេះ គប្បីសម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមផ្លូវច្បាប់ ហើយផ្តល់ស្ថានសម្រាលដល់ជនជាប់ចោទដោយការព្យួរទោសធម្មតា។



Scanned with CamScanner

## ២/.ផ្នែកសេចក្តីសម្រេច

ក. ផ្តន្ទាទោសជនជាប់ចោទ៖

ឈ្មោះ [redacted] វ៉ុន ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត ភូ[redacted] ខេត្តកំពង់ចាម អាសយដ្ឋានមុនពេលឃាត់ខ្លួន ភូមិព្រីត ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ឪពុកឈ្មោះ [redacted] ឃឹម (រ) ម្តាយឈ្មោះ [redacted] សុខន (រ) ប្រពន្ធឈ្មោះ [redacted] ស្រីម៉ៅ មានកូនចំនួន០២នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

ដាក់ពន្ធនាគារកំណត់រយៈពេល០១(មួយ)ឆ្នាំគត់ ប៉ុន្តែទោសនេះត្រូវអនុវត្តទោសព្យួរធម្មតា។

ពីបទ ហិង្សាដោយចេតនា ប្រព្រឹត្តិនៅភូមិព្រីត ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

ខ. សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈដោយសម្រេចសេចក្តីកំបាំងមុខជនជាប់ចោទ ឈ្មោះ ឃឹម វ៉ុន។

**បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។**

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និងត្រា** [redacted]

**ចៅក្រមជំនុំជម្រះ**
**ហត្ថលេខា និងត្រា** [redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ធ្វើនៅសាលាដំបូង ត្បូងឃ្មុំ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២
**ក្រឡាបញ្ជី**
[redacted]

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**
[redacted]



Scanned with CamScanner